**San Diego Unified**
School District

EUGENE BRUCKER EDUCATION CENTER
Office of Dropout Prevention
4100 Normal Street, Room 2228, San Diego, CA 92103-2682

(619) 725-7388
Fax: (619) 725-7180

## Valenzuela/កម្មវិធីបំរើ និងបង្រៀនវិញ្ញាសារប្រឡង CAHSEE ឲ្យបានគ្រប់គ្រាន់ ដើម្បីសម្រុះសម្រួលដោះស្រាយការតវ៉ា

## ដំណឹងពត៌មានសំរាប់សិស្ស

> សម្គាល់: ច្បាប់អប់រំមាត្រាលេខ 37254 តម្រូវឡើងថា លិខិតពត៌មាននេះត្រូវតែតាំងបិតទៅក្នុងការិយាល័យសាលារៀនមួយៗ ដែលបំរើសិស្សចាប់ពីថ្នាក់ទី ១០-១២, ការិយាល័យក្រសួងអប់រំប្រចាំក្រុង, ព្រមទាំងដាក់ទៅតាមប្រព័ន្ធ អ៊ីនធឺណែត website របស់ក្រសួងអប់រំប្រចាំក្រុង ។ លិខិតពត៌មាននេះត្រូវតែបកប្រែជាភាសាទូទៅទាំងអស់ដែលតម្រូវឡើងដោយច្បាប់អប់រំមាត្រាលេខ 48985 ។

### ពត៌មានសំរាប់មាតាបិតា/អ្នកអាណាព្យាបាល ព្រមទាំងសិស្សានុសិស្ស:
### សិស្សដែលអាចទទួលជំនួយសិក្សាដើម្បីប្រុងប្រៀបខ្លួនប្រឡងវិញ្ញាសារ CALIFORNIA HIGH SCHOOL EXIT EXAM អោយបានជាប់ ក្រោយពេលរៀនចប់ថ្នាក់ទី ១២

មាតាបិតា/អ្នកអាណាព្យាបាល ព្រមទាំងសិស្សានុសិស្ស:

ដើម្បីអនុលោមទៅតាមច្បាប់អប់រំប្រចាំរដ្ឋ California មាត្រាលេខ 37254 តាមរយះនេះ អ្នកនឹងបានទទួលដំណឹងថា:

១. សិស្សានុសិស្ស រួមនឹងសិស្សរៀន English ណាដែលប្រឡងវិញ្ញាសារ California High School Exit Examination (CAHSEE) មិនបានជាប់ មួយផ្នែក ឬទាំងពីរផ្នែក ពេលរៀនចប់ថ្នាក់ទី ១២ នឹងបានទទួលការបង្រៀន និងការបំរើអោយបានគ្រប់គ្រាន់ រហូតដល់ទៅពីរឆ្នាំជាប់ៗគ្នា ក្រោយពេលរៀនចប់ថ្នាក់ទី ១២ ឬ រហូតទាល់តែប្រឡងវិញ្ញាសារ CAHSEE ទាំងពីរផ្នែកអោយបានជាប់ ឬមួយណាបានជាប់មុន;

២. សិស្សរៀន English ណាដែលប្រឡងវិញ្ញាសារ CAHSEE មិនបានជាប់ មួយផ្នែក ឬទាំងពីរផ្នែក ពេលរៀនចប់ថ្នាក់ទី ១២ នឹងបានទទួលការបំរើបង្រៀនដើម្បីបង្កើនការសិក្សាផ្នែក English អោយបានគ្រប់គ្រាន់ ដើម្បីប្រឡងវិញ្ញាសារ CAHSEE ផ្នែកដែលមិនបានជាប់រហូតទាល់តែបានជាប់ ដល់ទៅពីរឆ្នាំជាប់ៗគ្នា ក្រោយពេលរៀនចប់ថ្នាក់ទី ១២ រហូតទាល់តែប្រឡងវិញ្ញាសារ CAHSEE ទាំងពីរផ្នែកអោយបានជាប់, មួយណាបានជាប់មុន; និង

៣. សិស្សដែលប្រឡងវិញ្ញាសារ CAHSEE មិនបានជាប់មួយផ្នែក ឬទាំងពីរផ្នែក ពេលរៀនចប់ថ្នាក់ទី ១២ មានសិទ្ធិធ្វើការតវ៉ាបាន ស្តីអំពីការបង្រៀន និងការបំរើអោយបានគ្រប់គ្រាន់ ក្រោមច្បាប់ទម្រង់តវ៉ា បើសិស្សនោះមិនមានឱកាសទទួលការបង្រៀន និងការបំរើអោយបានគ្រប់គ្រាន់ ចំនួនពីរឆ្នាំជាប់ៗគ្នា ក្រោយពេលរៀនចប់ថ្នាក់ទី ១២ ឬទទួលការបំរើរហូតទាល់តែប្រឡងជាប់វិញ្ញាសារ CAHSEE ផ្នែកទាំងពីរនេះបានជាប់, មួយណាបានជាប់មុន។

បើលោកអ្នកមានសំនួរអ្វីមួយស្តីអំពី ការបំរើនេះ, មានបំណងត្រូវការការបំរើនេះ ឬមានបំណងតវ៉ាស្តីអំពី ការបំរើនេះ សូមធ្វើការទាក់ទងជាមួយ Linda Trousdale ដែលមានអស័យដ្ឋាននៅ, 4100 Normal Street, Room 3150, San Diego, CA 92103 ឬទូរស័ព្ទលេខ (៦១៩) ៧២៥-៧៣៤២ និង via E-mail: lindatrousdale@sandi.net.